# ដំណាំស្ពៃផ្កា

## ការរៀបចំដីដាំ

- រៀបចំរងទំហំ៨០ សង់ទីម៉ែត្រ (ត្រូវមានកំពស់ ៣០ សង់ទីម៉ែត្រយ៉ាងតិចនៅរដូវវស្សា)
- ពង្រាយជីលាមកគោស្ងួតរឺជីកំប៉ុស្ត៍ និងជីកែង៧ពេញរងហើយកាប់ប្រចល់ជាមួយដីអោយសព្វល្អ
- គ្របរងដោយ ចំបើងអោយបានកំរាស់យ៉ាងតិច៥សង់ទីម៉ែត្រ រឺប្រើគំរបដីផ្លាស់ស្ទិក ដើម្បីការពារស្មៅចង្រៃ និងរក្សាសំណើមដី

## ការបណ្តុះកូន

ដើម្បីអោយបានកូនស្ពៃផ្កាដែលមានសុខភាពល្អ យើងត្រូវបណ្តុះកូនតាមរបៀបខាងក្រោមៈ

- រៀបចំកន្ទោងបណ្តុះ (ស្លឹកត្នោត រឺស្លឹកចេក) រឺ ថាសបណ្តុះ
- យកដីមានជីជាតិ (ដីដំបូក) ១ភាគ ជីកំប៉ុស្តិ៍ រឺ ជីលាមកគោដែលរលួយ ១ភាគ និងផេះអង្កាម ១ ភាគ លាយជាមួយគ្នាហើយយកទៅលីងអោយក្តៅបំផុត រួចទុកអោយត្រជាក់ទើបដាក់កន្ទោង។ បើមិនលីងល្បាយដីទេ កូនដំណាំងាយមានជំងឺផ្សិត ធ្វើឱ្យលួយបាន។
- បណ្តុះតែ១គ្រាប់ក្នុងមួយកន្ទោង ត្រូវគ្របសំណាញ់សត្វល្អិត និងធ្វើដំបូលគ្របអំពីស្លឹកដូង រឺ សំណាញ់កាត់ពន្លឺនៅរដូវក្តៅ។ រដូវវស្សាត្រូវធ្វើដំបូលការពារទឹកភ្លៀង ពីព្រោះកូនដំណាំនៅតូចមិនត្រូវការពន្លឺ និងទឹកច្រើនទេ។
- ស្រោចទឹក១ថ្ងៃមួយដងនៅពេលព្រឹក (បើទុកដីបណ្តុះស្ងួត គ្រាប់មិនអាចដុះបានទេ បើកូនដុះហើយក៏នៅក្រិនដែរ)

**កូនដំណាំមានសុខភាពល្អ ជួយអោយដំណាំធំលឿន កាត់បន្ថយការបំផ្លាញពីជំងឺ សត្វល្អិត និងទទួលទិន្នផលបានស្មើគ្នា**

## ការដាំកូនស្ពៃផ្កា

- ត្រូវដាក់កូនស្ពៃផ្កាអោយត្រូវចំពន្លឺថ្ងៃបានចំនួន ២-៣ថ្ងៃមុនដាំ ដើម្បីអោយកូនរឹងមាំល្អហើយផ្សាំ និងអាកាសធាតុខាងក្រៅបាន ។
- កូនស្ពៃផ្កាអាយុបាន ១៨-២២ថ្ងៃ អាចយកទៅដាំបាន (តែអាស្រ័យតាមការថែទាំកូន )
- ស្រោចទឹកកូនស្ពៃផ្កាអោយសើមល្មមនៅពេលព្រឹក ហើយចាប់ផ្តើមដានៅពេលរសៀល
- យកកូនចេញពីកន្ទោង រឺថាសបណ្តុះដោយប្រុងប្រយ័ត្នបំផុតមិនត្រូវអោយដាច់ឫសកូនស្ពៃផ្កាឡើយ ព្រោះវាធ្វើអោយកូនស្ពៃផ្កាអន់បាននៅពេលដាំ។
- ត្រូវស្រោចទឹកកូនស្ពៃផ្កាអោយបានគ្រប់គ្រាន់បន្ទាប់ពីដាំហើយ ជាពិសេសរវាងពី ២-៣ អាទិត្យបន្ទាប់ពីដាំកូនហើយ

## ការថែទាំ

- ត្រូវស្រោចទឹកអោយបានគ្រប់គ្រាន់នៅពេលព្រឹក  ជៀសវាងស្រោចទឹកច្រើនពេកធ្វើអោយដីសើមជ្រុលនៅពេលថ្ងៃល្ងាច វាអាចបង្កអោយមានបញ្ហាដល់ ដំណាំបាន។
- ពេលផ្កាបានទំហំពី ៤ ស.ម យើងចាប់ស្លឹកអមផ្កាពត់រកគ្នាខ្ទាស់អោយជាប់ដើម្បីបាំងពន្លឺ   និង កំដៅថ្ងៃរហូតដល់ផ្ការីកធំល្មមកាត់។
- បេះស្លឹកនៅផ្នែកខាងក្រោមចោល (ស្លឹកទុំ)



EAST-WEST SEE

**ការប្រើប្រាស់ជី** ( បើដាក់ជីត្រូវស្រោចទឹក ទើបដំណាំអាចចាប់យកជីបាន)

| ពេលវេលា | ប្រភេទជីប្រើ | កន្លែងដែលត្រូវដាក់ជី |
|---|---|---|
| ទ្រាប់បាត | **ជី អិន ប៉េ កា (១៥. ១៥.១៥)**៣០ក្រាម (៣ស្លាបព្រាបាយស្មើ)/ម៉ែត្រការ៉េ<br>**ជីលាមកសត្វ** ១.៥ គីឡូក្រាម/ម៉ែត្រការ៉េ | ពង្រាយលើរងហើយកាប់ច្របល់និងដី |
| **ការដាំកូន** | **១ដើម/រណ្តៅ** (កូនស្ពៃអាយុ ១៨-២២ថ្ងៃចាប់ផ្តើមដាំ) | |
| ១ អាទិត្យបន្ទាប់ពីដាំ | **ជីអ៊ុយរ៉េ** ២.៥ ក្រាម (១ចុងស្លាបព្រាបាយ)/ដើម | កប់ជីរាក់ៗ ចំងាយពីគល់កន្លះតឹក |
| ២អាទិត្យបន្ទាប់ពីដាំ | **ជី អិន ប៉េ កា (១៥. ១៥.១៥)** ៧.៥ ក្រាម (១ស្លាបព្រាបាយស្មើ)/ដើម | កប់ជីរាក់ៗ ចំងាយពីគល់១តឹក |
| ៣ អាទិត្យបន្ទាប់ពីដាំ | **ជី អិន ប៉េ កា (១៥. ១៥.១៥)** ៣.៧៥ ក្រាម (១ចុងស្លាបព្រាបាយ)/ដើម<br>**ជីប៉ូតាស្យូម** ២ក្រាម (១ចុងស្លាប ព្រាបាយ)/ដើម | កប់ជីរាក់ៗ ចំងាយពីគល់ ១តឹកកន្លះ |
| ៤ អាទិត្យបន្ទាប់ពីដាំ | **ជី អិន ប៉េ កា (១៥. ១៥.១៥)៣.៧៥** ក្រាម (១ចុងស្លាបព្រាបាយ)/ដើម | កប់ជីរាក់ៗ ចំងាយពីគល់ ១តឹកកន្លះ |

**ជំងឺនិងសត្វល្អិត**

- សូមឧស្សាហ៍ពិនិត្យរកមើលពងដង្កូវ និងកូនដង្កូវនៅខាងក្រោមស្លឹក ហើយញុចវាសំបុកដង្កូវចោល ។
- បើទុកដង្កូវនេះអោយធំ នោះពិបាក និង កំចាត់វាណាស់ ទោះបាញ់ថ្នាំពុលក៏ពិបាកសំលាប់វាដែរ ហើយដង្កូវវាងាយលាក់ខ្លួនក្នុងដី ។
- សូមដកដើមស្ពៃផ្កាចេញភ្លាមបន្ទាប់ពីបញ្ចប់ប្រមូលផលហើយ ។ កុំទុកដើមដែលឈប់ប្រមូលផលហើយនៅនឹងក្នុងចំការ ។ ពីព្រោះវាជាជំរកសត្វល្អិតនិងជំងឺបំផ្លាញទៅដំណាំផ្សេងទៀតបាន ។

**ប្រការចងចាំ**

- កុំប្រើថ្នាំឈ្មោះកំចាត់សត្វល្អិតនិងជំងឺដដែលៗ វាធ្វើអោយសត្វល្អិតនិងជំងឺធន់ទ្រាំជាមួយថ្នាំ ពិបាកកំចាត់នៅ ពេលក្រោយ ។
- កុំប្រើថ្នាំពុលលាយចូលគ្នានៅពេលបាញ់ វាធ្វើអោយថ្នាំគ្មានប្រសិទ្ធិភាព ហើយសត្វល្អិត ដង្កូវរប៉ស់សាំនិងថ្នាំ ពិបាកកំចាត់វាពេលក្រោយ ។ ជាពិសេសកុំប្រើថ្នាំដែលមានវណ្ណពណ៌ក្រហម **(សញ្ញាក្បាលខ្មោច)** វាគ្រោះថ្នាក់ ដល់សុខភាពខ្លាំងណាស់ ។
- កុំបាញ់នៅពេលមេឃជិតធ្លាក់ភ្លៀង មានខ្យល់ និងនៅពេលថ្ងៃត្រង់ ។
- សូមកុំដាំពពួកអំបូរស្ពៃលើដីដដែល វាបង្កអោយមានជំងឺ និងសត្វកើតឡើងច្រើនពិបាកកំចាត់វាណាស់ ។

**ការប្រមូលផល**

- កាត់ផ្កាស្ពៃពេលព្រឹក ដោយរក្សាទុកស្លឹកអមផ្កា៤ ទៅ ៥ និងត្រូវទុកផ្កាដែលកាត់ហើយក្នុងម្លប់ ។



EAST-WEST SEE